01374495

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 01 / 2017
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/504

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦

## សវនាការលើភ័ស្តុតាង - ថ្ងៃ ៤៨៥

រៀបចំដោយ៖ លោក **ឯម ហ៊ិយ** និង កញ្ញា Evelyn CAMPOS SANCHEZ

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម Claudia FENZ , ចៅក្រម ធូ មណី |
| ចៅក្រមបំរុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ិយ, កញ្ញា Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត , លោក Vincent De Wilde d'ESTMALE, លោក Nicholas KOUMJIAN |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ,លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marrie Guiraud, លោក |

| |
|---|
| ហុង គីមសួន, លោក វ៉ែន ពៅ, លោកស្រី ស៊ិន សុវ៉ន , លោកស្រី ទី ស្រ៊ានណា |
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ ដើមបណ្តឹង ខៀវ នាប (2-TCCP-258) , 2-TCCP-1063 |
| មេធាវីប្រឹក្សាសាក្សី៖ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួរ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, កញ្ញា យស សេរីរ័ត្ន, លោកស្រី សំ មករា, លោក នូ មនោរ័ត្ន, លោក មៀច សុវណ្ណា, កញ្ញា Elodie KANCEL |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០២ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៨ | បញ្ចប់ម៉ោង៖ ១០.៣៨ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣០ | បញ្ចប់ម៉ោង៖ ១៣.៣៣ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.១២ | បញ្ចប់ម៉ោង៖ ១៤.៣០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង និង ១៧ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ, ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៦ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៦ | ០៩.០៧ |
| សេចក្តីសម្រេចផ្ទាល់មាត់ក្នុងការទទួលពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063 | អង្គជំនុំជម្រះ | ០៩.០៨ | ០៩.១០ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប (2-TCCP-258) | សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.១០<br>១០.៥៥<br>១៣.៣៣ | ១០.១១<br>១១.៣០<br>១៤.១២ |
| សារណា និងសេចក្តីសម្រេចផ្ទាល់មាត់ស្តីពីស្តាប់សក្ខីកម្មសាក្សី 2-TCW-1069 | អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា | ១០.១១<br>១១.២៩ | ១០.១៣<br>១១.២៩ |

| | | | |
|---|---|---|---|
| ដែលបានស្នើឡើងកាលពីថ្ងៃសុក្រទី០១ ខែ ធ្នូ ឆ្នាំ ២០១៦ នៅវគ្គរសៀល | សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី ខៀវ សំផន<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា | ១០.១៣<br>១០.១៤<br>១០.១៧<br>១០.១៨<br>១០.៣៨ | ១០.១៤<br>១០.១៥<br>១០.១៨<br>១០.១៩<br>១០.៤២ |
| ការតាំងសំណួរទៅកាន់ សាក្សី 2-TCW-1063 | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា | ១៤.៣៥<br>១៤.៣៩<br>១៥.៤១ | ១៤.៣៩<br>១៥.៤១<br>១៦.០១ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**សេចក្តីសម្រេចផ្ទាល់មាត់ក្នុងការទទួលយកពាក្យសុំតាំងខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី(2-TCCP-1063)**

អង្គជំនុំជម្រះកត់សំគាល់ថា ពាក្យសុំតាំងខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី (2-TCCP-1063) ដែលបច្ចុប្បនេះមានលេខឯកសារ D22/194 ។ នៅពេលថ្មីៗនេះ អង្គជំនុំជម្រះ បានទទួលយកទំរង់បែបបទព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើជាឯកសារភស្តុតាង ដែលមានលេខឯកសារ E3/10670 (សូមមើលឯកសារ E436/1)។ ទំរង់បែបបទព័ត៌មានបន្ថែមផ្សេងទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបាននទទួលយកជាឯកសារភស្តុតាងកាលពីមុន ហើយមានលេខឯកសារ E3/5932a ។ ផ្អែកលើការអនុវត្តរបស់អង្គជំនុំជម្រះ ទាក់ទងទៅនឹងការទទួលយកសម្ភារៈ ទាក់ទងនឹងបុគ្គលនានាដែលនឹងត្រូវមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំម្រះ ហេតុដូច្នេះហើយ អង្គជំនុំជម្រះ ទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063 ធ្វើជាឯកសារភស្តុតាង និងដាក់លេខឯកសារ E3/10670a សម្រាប់ឯកសារនោះ។

**<u>ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប (2-TCCP-258)</u>**

សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប (2-TCCP-258)។

**<u>សារណា និងសេចក្តីសម្រេចផ្ទាល់មាត់ក្នុងការស្តាប់សក្ខីកម្មរបស់សាក្សី 2-TCW-1069 ដែលបានស្នើឡើងកាលពីថ្ងៃសុក្រ ទី ០១ ខែ ធ្នូ ២០១៦ នៅវគ្គរសៀល</u>**

អង្គជំនុំជម្រះបានអញ្ជើញភាគីទាំងអស់ឱ្យបង្ហាញអំពីការកត់សំគាល់របស់ខ្លួន ថាតើក្រុមខ្លួនបានត្រៀមរួចរាល់ហើយឬនៅ ក្នុងការតាំងសំណួរទៅកាន់សាក្សី 2-TCW-1069 នៅវគ្គរសៀលថ្ងៃទី ០១ ខែ ធ្នូ ២០១៦ នេះ ។ មេធាវីការពារក្តី នួន ជា បានលើកឡើងថា ខ្លួនមានលទ្ធិភាពគ្រប់គ្រាន់ក្នុងការពិនិត្យឯកសារបកប្រែភាសាអង់គ្លេសនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី 2-TCW-1069 និង 2-TCW-1070 របស់មជ្ឈមណ្ឌលឯកសារ DC-Cam ដែលនឹងត្រូវប្រើប្រាស់ក្នុងការតាំងសំណួរទៅ កាន់សាក្សី 2-TCW-1069 ។ សហព្រះរាជអាជ្ញាបាននិយាយថា ខ្លួនបានត្រៀមរួចរាល់ក្នុងការស្តាប់សំណួររបស់ក្រុមមេធាវីការពារក្តី ប៉ុន្តែនឹងត្រៀមខ្លួនតាំងសំណួរទៅកាន់សាក្សីនៅក្នុងអំឡុងពេលសប្តាហ៍បន្ទាប់ ហើយបានបន្ថែមទៀតថា ខ្លួនមិនមានមូលហេតុណាមួយ ដើម្បីពន្យាពេលសវនាការនោះទេ ប្រសិនបើមានដំណោះស្រាយផ្សេងទៀតអាចទទួលយកបានចំពោះឯកសារទាំងនោះ ។ មេធាវីការពារក្តី ខៀវ សំផន បាននិយាយថា ខ្លួនមិនទាន់បានត្រៀមខ្លួនរួចរាល់នោះទេ ហើយថា បើមានការប្រញាប់ប្រញាល់ពេក នឹងធ្វើឱ្យមានកំហុសក្នុងការរៀបចំ ។ នៅពេលដែលការបកប្រែឯកសារពាក់ព័ន្ធ បានរួចរាល់អស់ហើយ អង្គជំនុំជម្រះនឹងសម្រេចទៅលើការកំណត់កាលវិភាគសវនាការសម្រាប់ការស្តាប់សក្ខីកម្មសាក្សី 2-TCW-1069 នៅវគ្គរសៀល ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦ នេះ ។

**<u>ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ២០១៦ 2-TCCP-1063</u>**

អង្គជំនុំជម្រះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063 ។

New E3s

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/6425 | - | 00544162-00544176; 01114147-01114160; 01152689-01152693 | Civil party application of THEAV Neab 08-VU-00436 | P | 00544168 ; 00544170 | 01114153; 01114154 | 01152692 ; 01152693 |
| E3/6425 a | D22/ 2038a | 00581516-00581522; 01069299-01069303; 01151393-01151397 | Supplementary information of civil party applicant | P | 00581519 | 01069300 | 01151395 |
| E3/10454 | - | 01018811-01018815; - - | Name of prisoners killed on 2/12/78 | P | - | - | - |
| E3/1974 | - | 00052897-00052900; 00184007-00181009; 00884076-00884080 | Name of prisoners of Foreign Affairs, State Sewing and State Economy Ministry's Section | P | 00052897 | 00184007-08 | 00884077 |
| E3/2178 | D100 /26.1 40 | 00021090-00021091; 00631977-00631982; 00855396-00855401 | S-21 Prisoner List containing names of prisoners from the General Staff Office | P | 00021091 | 00631981 | 00855400 |
| E3/5542 | - | 00381012-00381022; 00373225-00373231; 00381118-00381130 | Written Record of Interview of Civil Party IN Vuthy | P | - | - | - |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/7708 | - | 00242402-00242405; 00250739-00250742; 00274496-00274499 | Written Record of Interview of Civil Party of DUONG Sau | C | - | - | - |
| E3/3970 | D296/10 | 00422470-00422481; 00434928-00434938; 00448663-00448674 | Written Record of Interview of Civil Party PECH Srey Phâl | P | - | - | - |
| E3/9479 | E319/12.3.9 | 01008715-01008728; 01044691-01044705; 01120135-01120146 | Written Record of Interview of Civil Party KHEAV Neap | C | 01008720-21; 01008727 | 01044697; 01044704 | 01120139-40; 01120145 |
| E3/342 | D288/6.68.1 | (KH, ENG) 00329596-00330129; - | Revised S-21 Prisoner List | P | 00329780 | 00329780 | - |
| E3/5932a | D22/194a | 00578455-00578456; 01332267-01332269; - | Supplementary information of civil party applicant | C | 00578455 | 01332268 | - |
| E3/10670 | E319/57.2.7 | 01118427-01118432; 01190620-01190625; - | Supplementary Information | C | 01118429 | 01190623 | - |
| E301/9/1 | - | 00981701-00981733; 00981666-00981686; 00982098-00982123 | Decision on Additional Severance of Case 002/02 and Scope of Case 002/02 | P | 00981727 | 00981682 | 00982118 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៧)
- សេចក្ដីសម្រេចផ្ទាល់មាត់ក្នុងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារ D22/194 ជាឯកសារភ័ស្តុតាងថ្មី ឯកសារលេខ E3/10670a ។ (០៩.១០)
- សេចក្ដីសម្រេចផ្ទាល់មាត់លើការកំណត់កាលវិភាគសវនាការសម្រាប់ការស្ដាប់សក្ខីកម្មសាក្សី 2-TCW-1069 នៅវគ្គរសៀលថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦ ។ (១១.២៩)
- បង្គាប់ឱ្យហៅដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-1063 តែរហស្សនាមតែប៉ុណ្ណោះ ដោយសារដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ស្ថិតក្នុងកិច្ចស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេត និងស្ថិតនៅក្នុងក្រុម ក នៃឯកសារ E390/35 ។ (១៤.៣១)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹកនៅថ្ងៃពុធ ទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦ ។ (១៦.០២)

| <u>**កាលវេលាសវនាការបន្ត**</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី [illegible] ២០១៦

ក្រឡាបញ្ជី [illegible] ក្រឡាបញ្ជី

លោក **ឯម ហ៊ុយ** [illegible] លោកស្រី Evelyn CAMPOS SANCHEZ